# ព្រឹត្តិបត្រក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ព័ត៌មានថ្មីៗអំពីទំនាក់ទំនងវិជ្ជាជីវៈ និងការដោះស្រាយវិវាទការងារនៅកម្ពុជា**

ខែមករា-មីនា ឆ្នាំ២០១២

**ដោះស្រាយវិវាទការងាររួម**

## មាតិកា


- របាយការណ៍បច្ចុប្បន្នភាព ស្តីពីការដោះស្រាយវិវាទការងាររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ១
- សវនាការចល័តទទួលបានលទ្ធផលកិច្ចព្រមព្រៀងសះជា ២
- កម្មករនិយោជិតចំនួន ៤០០នាក់ បញ្ឈប់កូដកម្ម ដើម្បីធ្វើការដោះស្រាយវិវាទតាមសន្តិវិធី ៣
- អាជ្ញាកណ្តាលបានផ្សះផ្សាភាគីអោយសះជាចំណុចវិវាទ២៨ ក្នុងចំណោមចំណុចទាមទារចំនួន២៩ ៣
- និរន្តរភាពនៃការដោះស្រាយវិវាទការងាររួមតាមអាជ្ញាកណ្តាលគឺជាបញ្ហាប្រឈមរួម សម្រាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងអ្នកប្រើប្រាស់សេវាកម្មរបស់ស្ថាប័ននេះ ៤
- តុលាការកម្ពុជា គាំទ្រសេចក្តីសម្រេចក្រុមប្រឹក្សាអាជ្ញាកណ្តាល ៥
- អាជ្ញាកណ្តាលនិងចៅក្រមពិភាក្សាស្តីពីក្រមនីតិវិធីរដ្ឋប្បវេណីថ្មី ៥
- អ្នកឯកទេសផ្នែកការងារចូលរួមជាសមាជិកគណៈកម្មការប្រកួតអាជ្ញាកណ្តាល អន្តរជាតិប្រឌិតដំណាក់កាលដំបូង ៦
- តើមានអ្វីថ្មី? ៧
- ទទួលនូវព័ត៌មានបច្ចុប្បន្នភាពស្តីពីច្បាប់ការងារថ្មី? ៨


## ព័ត៌មានបច្ចុប្បន្នភាពស្តីពីការដោះស្រាយវិវាទ ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ស្ថិតិការដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល




គិតមកដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១២ មានសំណុំរឿងចំនួន៧០ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីដោះស្រាយដោយនិយោជក សហជីព និងកម្មករនិយោជិត។ ក្នុងចំណោមសំណុំរឿងទាំង៧០នេះ មាន២២សំណុំរឿងត្រូវបានដោះស្រាយដោយជោគជ័យតាមរយៈកិច្ចព្រមព្រៀងសះជាគ្នារវាងគូភាគីវិវាទ ហើយសំណុំរឿងចំនួន៣២ទៀត ត្រូវបានដោះស្រាយតាមរយៈការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល។

សំណុំរឿងដែលនៅសេសសល់ចំនួន ១៦ ទៀត នៅកំពុងដំណើរការនៅឡើយ ហើយត្រូវបានបញ្ជូនទៅខែបន្ទាប់ដើម្បីធ្វើការដោះស្រាយ ។ ក្រាហ្វិចខាងលើ បង្ហាញពីការកើនឡើងយ៉ាងខ្លាំងនូវចំនួនសំណុំរឿងវិវាទ ប្រសិនបើប្រៀបធៀបជាមួយចំនួនសំណុំរឿងដែលបានចុះបញ្ជីនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅត្រីមាសទី១ នៃឆ្នាំនេះជាមួយនឹងត្រីមាសទី១នៅឆ្នាំមុន។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលបានសំណុំរឿងចំនួន ៧០ នៅក្នុងត្រីមាសទី១ នៅឆ្នាំ២០១២ ប្រសិនបើប្រៀបធៀបទៅនឹងសំណុំរឿងចំនួន៤៤ នៅក្នុងអំឡុងពេលដូចគ្នានេះ កាលពីឆ្នាំ ២០១១ ។ ការកើនឡើងចំនួនសំណុំរឿងនេះបង្ហាញឲ្យឃើញពីការពេញចិត្តរបស់ក្រុមហ៊ុន និងកម្មករនិយោជិតកម្ពុជា ចំពោះការប្រើប្រាស់សេវាកម្មដែលប្រកបដោយវិជ្ជាជីវៈរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។







*សវនាការនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល*

តារាងនេះបង្ហាញអំពីសំណុំរឿង នៃវិវាទអំពីសិទ្ធិ និងសំណុំរឿងវិវាទអំពីផលប្រយោជន៍នៅក្នុងសំណុំរឿងដែលបានចេញជាសេចក្តីបង្គាប់ទាំងអស់ដែលគ្របដណ្តប់ដោយអនុស្សារណៈយោគយល់គ្នានៅក្នុងអំឡុងពេលរបាយការណ៍នេះ។ ពីខែមករា ដល់ខែមីនា ឆ្នាំ២០១២ មានសំណុំរឿងចំនួន៣១ ក្នុងចំណោមសំណុំរឿងសរុបចំនួន៧០ ដែលបានចុះបញ្ជីគ្របដណ្តប់ដោយអនុស្សារណៈយោគយល់គ្នានៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់។ ដូចដែលតារាងនេះបង្ហាញឲ្យឃើញស្រាប់ចំនួនភាគច្រើន(៦៧%)នៃវិវាទនៅក្នុងអនុស្សារណៈយោគយល់គ្នានេះគឺជាវិវាទអំពីសិទ្ធិ។ ជាករណីជាក់ស្តែងអនុស្សារណៈយោគយល់គ្នានេះ មានគោលដៅលើកកម្ពស់ទំនាក់ទំនងវិជ្ជាជីវៈឲ្យមានភាពសុខដុមរម្យនានៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់កម្ពុជា ដែលតាមរយៈអនុស្សារណៈនេះកម្មករនិយោជិតសន្យាថាមិនធ្វើកូដកម្មក្នុងខណៈដែលនិយោជកត្រូវគោរពទៅតាមសេចក្តីបង្គាប់អាជ្ញាកណ្តាល។ កិច្ចព្រមព្រៀងរវាងសមាគមរោងចក្រកាត់ដេរកម្ពុជា និងសហព័ន្ធសហជីព និងសម្ព័ន្ធសហជីពចំនួន៦ ត្រូវបានឯកភាពគ្នានៅឆ្នាំ២០១០ ហើយបានអនុវត្តន៍យ៉ាងមានប្រសិទ្ធភាពនៅដើមខែមករា ឆ្នាំ២០១១ ។

*តទៅទំព័រ ២*

*តពីទំព័រ ១*




តារាងខាងលើ បង្ហាញពីចំនួននិយោជក និងកម្មករនិយោជិត ដែលបានចូលរួមសវនាការ នៅក្រុមប្រឹក្សាអាជ្ញាកណ្តាលពីខែមករា ដល់ ខែមីនា ឆ្នាំ២០១២ ។ ជាសរុបមានចំនួន ៣០៩នាក់ ដែលបានចូលរួមសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅត្រីមាសទី១ នៃឆ្នាំ ២០១២។ ជាចំនុចជាក់លាក់ មាននិយោជក ៨៤រូប (២៧%) និងកម្មករនិយោជិត២២៥រូប (៧៣%)ហើយ ៣១% ជាស្ត្រី។ បើពិចារណាទៅលើភាពជាក់ស្តែងស្ត្រីគឺជាចំនួនភាគច្រើននៅក្នុងកម្លាំងកម្មករផ្នែកកាត់ដេរ និងស្បែកជើង ដូចនេះក្រុមប្រឹក្សាអាជ្ញាកណ្តាលលើកទឹកចិត្តឲ្យស្ត្រីកាន់តែច្រើនក្នុងការចូលរួមសវនាការអាជ្ញាកណ្តាល ដើម្បីស្វែងយល់ឲ្យកាន់តែប្រសើរថា តើបញ្ហាវិវាទរបស់ពួកគេត្រូវបានដោះស្រាយដោយមិនលម្អៀង និងដោយមានប្រសិទ្ធិភាពតាមរបៀបណា ។

ជារួមក្រុមប្រឹក្សាអាជ្ញាកណ្តាលជួយដោះស្រាយវិវាទការងាររវាងនិយោជក និងសហជីព និងកម្មករនិយោជិតដោយមានអត្រាជោគជ័យចំនួន៧១.៣% ។ តាមរយៈការជួយដោះស្រាយនូវបញ្ហាវិវាទទាំងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលដើរតួនាទីយ៉ាងសំខាន់ ក្នុងការដោះស្រាយនូវឧបសគ្គនានាចំពោះផលិតភាពការងារ និងការសម្រេចបាននូវការងារស្ទួលរបស់សហគ្រាស និងកម្មករនិយោជិតហើយនោះគឺរក្សា និងព្យាយាមតម្លើងប្រាក់ចំណូលរៀងៗខ្លួនរបស់ពួកគេ ។

# សវនាការចល័តទទួលបានលទ្ធផលកិច្ចព្រមព្រៀងសះជា

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបើកសវនាការចល័តមួយនៅខេត្តសៀមរាបនៅ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១២ សម្រាប់សំណុំរឿងលេខ៥៦/១២ ដែលពាក់ព័ន្ធនឹងវិវាទការងារនៅក្រុមហ៊ុនដឺប្លូ ផាំឃីន ហើយបានបញ្ចប់វិវាទការងារនោះតាមរយៈកិច្ចព្រមព្រៀងសះជាគ្នារវាងក្រុមហ៊ុន និងកម្មករនិយោជិតរបស់ក្រុមហ៊ុននេះ ។

ក្រុមអាជ្ញាកណ្តាល ដែលមានសមាសភាពអាជ្ញាកណ្តាល **លោក ប៉ែន ប៊ុនឈា លោក ម៉ា សំបូរណា** និង**លោក ទូន ស៊ីផាន់** បានធ្វើការផ្សះផ្សាដោយជោគជ័យនូវចំនុចទាមទារចំនួន ៣ ដែលភាគីកម្មករបានលើកឡើងសម្រាប់ធ្វើការដោះស្រាយដោយក្រុមប្រឹក្សាអាជ្ញា កណ្តាល ។

**លោកស្រី សាយ សុខរស្មី** ប្រធានគ្រប់គ្រងផ្នែកធនធានមនុស្សនៅក្រុមហ៊ុន ដឺប្លូ ផាំឃីន មានសេចក្តីសោមនស្សរីករាយជាខ្លាំង ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានមកខេត្តសៀមរាប ដើម្បីធ្វើការដោះស្រាយវិវាទរវាងបុគ្គលិក និងថ្នាក់ដឹកនាំ ហើយបានជួយភាគីឲ្យសម្រេចបាននូវកិច្ចព្រមព្រៀងមួយនៅទីកន្លែងវិវាទនេះ។ គាត់បានបន្ថែមទៀតថា គាត់មានការជឿជាក់លើក្រុមប្រឹក្សាអាជ្ញាកណ្តាល ចំពោះឯករាជ្យរបស់ស្ថាប័ននេះ និងការផ្តោតយកចិត្តទុកដាក់ទៅលើយុត្តិធម៌ និងតម្លាភាព ។

" [អាជ្ញាកណ្តាលទាំង៣រូបនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលអនុវត្តនូវយុទ្ធសាស្ត្រ និងឥរិយាបទជារួមមួយ ទោះបីជាពួកគាត់ត្រូវបានជ្រើសរើសដោយភាគីហើយក៏ដោយហើយកិច្ចព្រមព្រៀងសះជាគ្នានោះ គឺមានលក្ខណៈយុត្តិធម៌ចំពោះភាគីទាំងសងខាង] " លោកស្រីបាននិយាយបន្ថែមថា " អាជ្ញាកណ្តាលទាំងអស់បានផ្តល់ការបកស្រាយយ៉ាងច្បាស់លាស់ នៅក្នុងការទាមទារនីមួយៗ ដែលធ្វើឲ្យភាគីទាំងអស់សំដែងការពេញចិត្ត " ។




*តំណាងសហគ្រាសនិងសហជីព បង្ហាញសំណុំរឿងរបស់ពួកគេនៅចំពោះមុខអាជ្ញាកណ្តាលក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងអំឡុងពេលសវនាការចល័តនៅខេត្តសៀមរាប*

**លោក សុខ ណារិទ្ធ** អនុប្រធានសហព័ន្ធសហជីពកម្មករនិយោជិក វិស័យទេសចរណ៍សេវាកម្មកម្ពុជា ក៏បានទទួលយកនូវកិច្ចព្រមព្រៀងដែលជួយផ្សះផ្សាដោយក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ ដោយលោកបាននិយាយថា ការពន្យល់របស់អាជ្ញាកណ្តាលគឺសុទ្ធតែផ្អែកទៅលើច្បាប់ការងារ ។

"ជាយូរណាស់មកហើយ ខ្ញុំបានទទួលស្គាល់ពីសារៈប្រយោជន៍នៃការប្រើប្រាស់សេវាកម្មរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រាប់ការដោះស្រាយវិវាទនៅក្នុងសំណុំរឿងនេះ។ ការចចារដំបូងជាមួយនិយោជកមិនបានផ្តល់ជាលទ្ធផលអ្វីនោះទេ" គាត់បាននិយាយ ។ "នៅពេលដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានមកជួយផ្សះផ្សាវិវាទយើងត្រូវបានដោះស្រាយដោយសន្តិវិធី" ។ ភាគីទាំងសងខាងបានថ្លែងអំណរគុណដល់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ហើយបានបង្ហាញនូវសេចក្តីសង្ឃឹមថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងបន្តបើកសវនាការចល័តតទៅទៀត ពោលគឺមិនមែនត្រឹមតែនៅក្នុងខេត្តសៀមរាបប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅក្នុងបណ្តាខេត្តផ្សេងៗទៀត ដែលនៅខាងក្រៅការិយាល័យរបស់ខ្លួននៅក្នុងទីក្រុងភ្នំពេញ ។ លោកស្រី សាយ សុខរស្មី បាននិយាយថា ប្រសិនបើអាចទៅរួច ខ្ញុំសូមសំណូមពរឲ្យក្រុមប្រឹក្សាអាជ្ញាកណ្តាល បង្កើតការិយាល័យនៅខេត្តផ្សេងទៀត ជាពិសេសគឺនៅខេត្តសៀមរាបដែលជាកន្លែងសំបូរទៅដោយសហគ្រាសជាច្រើន និងវិវាទការងារជាច្រើនផងដែរ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានបើកសវនការចល័តមួយទៀត នៅរសៀលថ្ងៃទី ២៣ ខែ មីនា នៅក្នុងសំណុំរឿង ៥៧/១២-ព្រលានយន្តហោះអន្តរជាតិ សៀមរាប ហើយបានធ្វើការផ្សះផ្សាសះជាចំណុចវិវាទចំនួន៥ ក្នុងចំណោមចំណុចវិវាទសរុបចំនួន៩ ដែលភាគីកម្មករនិយោជិតបានលើកឡើង។ សេចក្តីបង្គាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលសម្រេចទៅលើចំណុចវិវាទនៅសល់ចំនួន ៤ ទៀត នោះនឹងអាចរកបាននៅគេហទំព័រក្រុមប្រឹក្សាអាជ្ញាកណ្តាល http://www.arbitrationcouncil.org/awards/2012.html ។

# កម្មករនិយោជិតចំនួន ៤០០នាក់ បញ្ឈប់កូដកម្មដើម្បីធ្វើការ ដោះស្រាយវិវាទការងារតាមសន្តិវិធី


ថតដោយ ផា លីណា ភ្នំពេញប៉ុស្តិ៍


ភាគីនាំសំណុំរឿងមកក្រុមប្រឹក្សាអាជ្ញាកណ្តាល

កម្មករនិយោជិតចំនួនប្រហែល ៤០០ នាក់ ដែលបានតវ៉ានៅមុខរោងចក្ររបស់ពួកគេ គឺរោងចក្រ ឃៃ យ៉ាង (ខេមបូឌា) បានត្រឡប់ចូលធ្វើការវិញជាធម្មតា កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១២ បន្ទាប់ពីក្រុមប្រឹក្សាអាជ្ញាកណ្តាល បានចេញសេចក្តីបង្គាប់ឲ្យពួកគេត្រឡប់ចូលធ្វើការវិញ ដើម្បីរង់ចាំការដោះស្រាយវិវាទតាមសន្តិវិធី។

ការតវ៉ានោះបានចាប់ផ្តើមកាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ នៅរោងចក្រដែលមានទីតាំងនៅស្រុកអង្គស្នួល ខេត្តកណ្តាល ពាក់ព័ន្ធនឹងការទាមទារចំនួន៩ចំណុច។ ថ្នាក់ដឹកនាំរោងចក្រ និងតំណាងកម្មករ និយោជិតបានចរចាឯកភាពគ្នាលើចំណុចវិវាទចំនួន៧ ក្នុងចំណោមចំណុចវិវាទទាំង៩នេះ។ ចំណែកឯចំណុចទាមទារ ២ ដែលនៅទាស់ទែងគ្នា ត្រូវបានបញ្ជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ចំណុចវិវាទទាំងនោះគឺទាក់ទងនឹងការទាមទារឲ្យរោងចក្រទទួលស្គាល់សហជីពដែលទើបបង្កើតថ្មី និងឲ្យកម្មករនិយោ-ជិតដែលជាថ្នាក់ដឹកនាំសហជីពចំនួន៧រូប ចូលធ្វើការវិញ។

**លោក សេង សឿង** ថ្នាក់ដឹកនាំសហជីពមូលដ្ឋានរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា បានទទួលស្គាល់ថាកូដកម្មគឺបង្កការខូចខាតចំពោះភាគីទាំងសងខាង ហើយយល់ថាការដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលជាជម្រើសដ៏ប្រពៃជាង ។

" វាគឺល្អប្រសើរណាស់ ដែលឥឡូវនេះសំណុំរឿងវិវាទនេះបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ព្រោះថាក្រុមប្រឹក្សានេះ ជួយឲ្យកម្មករនិយោជិតត្រឡប់ចូលធ្វើការវិញដោយផ្តល់ភាពជឿជាក់ថាវិវាទការងាររបស់ពួកគេនឹងត្រូវបានដោះស្រាយដោយយុត្តិធម៌ " បើតាមប្រសាសន៍របស់លោក ។

**លោក គុប គឹមសាន** ប្រធានផ្នែករដ្ឋបាលរបស់រោងចក្របានឯកភាពថា វិវាទត្រូវតែដោះស្រាយដោយសន្តិវិធី ដើម្បីកុំឲ្យវិវាទទាំងនេះបង្កភាពរាំងស្ទះដល់សង្វាក់ផលិតកម្ម និងការបញ្ជាទិញពីអ្នកបញ្ជាទិញ ។

"ប្រសិនបើកូដកម្មកើតឡើងនោះយើងមិនអាចផលិតទំនិញរបស់យើងទាន់ពេលវេលានោះទេ។ ហេតុដូច្នេះហើយ អ្នកបញ្ជាទិញអាចដាក់ពិន័យយើង ឬលែងបន្តបញ្ជាទិញទំនិញពីយើងតទៅទៀត " នេះបើតាមសម្តីរបស់លោក ។

តំណាងរបស់រោងចក្រតៃវ៉ាន់រូបនេះបានបន្ថែមថា អន្តរាគមន៍ពីក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏អនុញ្ញាតឲ្យរោងចក្ររបស់គាត់មានប្រតិបត្តិការជាធម្មតាឡើងវិញដែរ ។

" វាជាការល្អប្រសើរណាស់ថា ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានចេញសេចក្តីបង្គាប់ឲ្យកម្មករនិយោជិតឈប់ធ្វើកូដកម្ម ដោយរង់ចាំសេចក្តីសម្រេចរបស់ក្រុមប្រឹក្សានេះ ដើម្បីដោះស្រាយវិវាទការងារ " នេះបើតាមប្រសាសន៍របស់លោក។ " កត្តានេះគឺល្អប្រសើរសម្រាប់ទាំងភាគីកម្មករនិយោជិត និងទាំងរោងចក្រផងដែរ។ "

ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានចេញសេចក្តីសម្រេចអាជ្ញាកណ្តាលដើម្បីដោះស្រាយសំណុំរឿងនេះ គឺសេចក្តីបង្គាប់លេខ១២ / ១២ - ឃៃ យ៉ាង (ខេមបូឌា) នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២។ សេចក្តីបង្គាប់នេះមាននៅលើគេហទំព័ររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅ http://www.arbitrationcouncil.org/awards/A_1212_K.pdf ។

# អាជ្ញាកណ្តាលបានផ្សះផ្សាភាគីអោយសះជាចំណុចវិវាទ២៨ ក្នុងចំណោមចំណុចទាមទារចំនួន២៩

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានផ្សះផ្សាដោយជោគជ័យនូវចំណុចវិវាទចំនួន២៨ ក្នុងចំណោម២៩នៅក្នុងសំណុំរឿងលេខ៣៣/១២-រោងចក្រដាយយ៉ាំង (សំណុំរឿងអនុស្សារណៈយោគយល់គ្នា ) ។ កិច្ចព្រមព្រៀងជាលាយលក្សណ៍អក្សរ ដែលបានសម្រេចឡើងតាមរយៈការផ្សះផ្សានោះសបញ្ជាក់ឲ្យឃើញពីការដោះស្រាយដោយមានប្រសិទ្ធិភាពតាមរយៈក្រុមប្រឹក្សាអាជ្ញាកណ្តាល ហើយសំខាន់ជាងគេទៅទៀតនោះ គឺការចូលរួមយ៉ាងពេញទំហឹងរបស់គូភាគីនៅក្នុងដំណើរការដោះស្រាយ ដើម្បីសម្រេចបាននូវការឈ្នះ ឈ្នះទាំងសងខាងដោយមិនចាំបាច់ប្រើប្រាស់នីតិវិធីតទល់គ្នាតាមផ្លូវច្បាប់ ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទៅលើចំណុចវិវាទដែលនៅសេសសល់ទាក់ទងនឹងសំណុំរឿងនេះគឺមាននៅលើគេហទំព័រក្រុមប្រឹក្សាអាជ្ញាកណ្តាល www.arbitrationcouncil.org/awards/2012.html។


អាជ្ញាកណ្តាលក្រុមប្រឹក្សាអាជ្ញាកណ្តាល កំពុងធ្វើការផ្សះផ្សាវិវាទរវាងគូភាគីនៅក្នុងអំឡុងពេលសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាល។

# និរន្តរភាពនៃការដោះស្រាយវិវាទការងាររួមដោយអាជ្ញាកណ្តាល គឺជាបញ្ហាប្រឈមរួម សម្រាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងអ្នកប្រើប្រាស់សេវាកម្ម ស្ថាប័ននេះ

ចាប់តាំងពីបង្កើតឡើងនៅឆ្នាំ២០០៣ មក ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការធ្វើឲ្យកាន់តែប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ និងបង្កើតនូវបរិយាកាសល្អប្រសើរសម្រាប់ការវិនិយោគនៅប្រទេសកម្ពុជា។ ក្រុមប្រឹក្សានេះដើរតួនាទីជាវេទិការដ៏គួរឲ្យជឿជាក់មួយសម្រាប់ការដោះស្រាយវិវាទការងារតាមសន្តិវិធី ដែលសហគ្រាស និងកម្មករនិយោជិតអាចប្រើប្រាស់បាន ហើយក៏អាចការនេះជួយពួកគេកាត់បន្ថយជាអប្បបរមានូវវិធានការឧស្សាហកម្ម និងភាពអាក់រអួលដល់ប្រតិបត្តិការសហគ្រាសរបស់ពួកគេ ។ នៅចុងខែមីនា ឆ្នាំ២០១២ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលវិវាទការងារចំនួនជាង១.២០០សំណុំរឿង ហើយបានដោះស្រាយសំណុំរឿងទាំងនេះដោយជោគជ័យក្នុងអត្រាប្រហែលជា៧១.៣%។ក្នុងខណៈពេលដែលក្រុមប្រឹក្សានេះផ្តល់សេវាទៅដល់វិស័យឧស្សាហកម្មទាំងអស់នោះក្រុមប្រឹក្សានេះទទួលសំណុំរឿងប្រហែលជា៩០%ពីវិស័យកាត់ដេរសំលៀកបំពាក់ដែលជាវិស័យសំខាន់របស់ប្រទេសកម្ពុជា ដែលផ្តល់ការងារជូនដល់កម្មករនិយោជិតប្រហែលជា៤០០.០០០នាក់នៅឆ្នាំ២០១១ ហើយក៏ជាវិស័យសំខាន់ទទួលខុសត្រូវក្នុងការនាំចេញរបស់កម្ពុជាប្រហែលជា៩០%ដោយមានចំនួនទឹកប្រាក់សរុបប្រហែល ៣,៣កោដិ ដុល្លារអាមេរិក ។

តាមបញ្ញត្តិច្បាប់សេវាកម្មដោះស្រាយវិវាទការងាររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវផ្តល់ជូនកម្មករនិយោជិត និងសហគ្រាសវិស័យឯកជនដោយឥតគិតថ្លៃ។ ដោយសារតែបញ្ហាប្រឈមរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រុមប្រឹក្សានេះត្រូវពឹងផ្អែកទៅលើថវិកាម្ចាស់ជំនួយខាងក្រៅ ដើម្បីផ្តល់សេវាដោះស្រាយវិវាទរបស់ខ្លួនមកដល់បច្ចុប្បន្ននេះ ។ បច្ចុប្បន្ននេះ សេវាដោះស្រាយវិវាទការងាររួមទទួលថវិកាឧបត្ថម្ភក្រោមគម្រោងអភិបាលកិច្ចល្អមូលដ្ឋានរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលគាំទ្រដោយធនាគារពិភពលោក ។ គម្រោងអភិបាលកិច្ចល្អមូលដ្ឋាននេះនឹងត្រូវបញ្ចប់នៅចុងខែមីនា ឆ្នាំ២០១៣។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល មិនទាន់បានទទួលនូវការសន្យាគាំទ្រផ្នែកហិរញ្ញវត្ថុជាក់លាក់ណាមួយ ដើម្បីគាំទ្រសេវាដោះស្រាយវិវាទការងាររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល បន្ទាប់ពីខែមីនា ឆ្នាំ២០១៣ បានបញ្ចប់នោះទេ ។ ការនេះបានបង្កឲ្យមានការព្រួយបារម្ភក្នុងចំណោមអ្នកប្រើប្រាស់ដោយផ្ទាល់នូវសេវាក្រុមប្រឹក្សាអាជ្ញាកណ្តាល និងភាគីពាក់ព័ន្ធដទៃទៀត ថាតើវិស័យឧស្សាហកម្ម និងកម្មករនិយោជិត ដែលធ្វើការនៅក្នុងវិស័យទាំងនោះនៅតែអាចបន្តនាំយកសំណុំរឿងវិវាទរបស់ពួកគេទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីដោះស្រាយដែរ ឬទេនៅពេលអនាគត ។

**លោក ភាន សុភា** ប្រធានសហជីពមូលដ្ឋានមួយរបស់សម្ព័នសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជាជឿជាក់ថា ប្រសិនបើគ្មានក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ នោះចំនួនវិវាទការងារនឹងកើនឡើងយ៉ាងខ្លាំង។ " ប្រសិនបើគ្មានក្រុមប្រឹក្សាអាជ្ញាកណ្តាលទេវិវាទការងារនឹងកាន់តែមានលក្ខណៈដុនដាបទៅៗ ទាំងចំនួនវិវាទ ទាំងទ្រង់ទ្រាយវិវាទ។" នេះបើតាមប្រសាសន៍លោក ភាន សុភា។ គាត់បានបន្ថែមថា គាត់គាំទ្រឲ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅបន្តសេវា ដែលមានលក្ខណៈឆាប់រហ័ស និងយុត្តិធម៌របស់ខ្លួន ។

**លោក ប៊ុន ធឿន** តំណាងនិយោជកនៅរោងចក្រ ខេមរីល អឹម អែប ជី យល់ឃើញថា ការបញ្ចប់គំរោងនៃសេវាអាជ្ញាកណ្តាល អាចជាការខាតបង់ដ៏ធ្ងន់ធ្ងរមួយសម្រាប់ប្រទេសកម្ពុជា និងអ្នកវិនិយោគ។ " បញ្ហានេះនឹងជះឥទ្ធិពលជាអវិជ្ជមានដល់កម្មករនិយោជិត និងនិយោជក ប្រសិនបើក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចផ្តល់សេវារបស់ខ្លួនបានតទៅទៀតទេនោះ» នេះបើតាមប្រសាសន៍របស់លោក ។ " នៅពេលដែលវិវាទមិនអាចដោះស្រាយដោយក្រសួងការងារបាន យើងមានក្រុមប្រឹក្សាអាជ្ញាកណ្តាល ហើយចំណាយពេលត្រឹមតែ១៥ថ្ងៃតែប៉ុណ្ណោះ ។

**លោក ឡាយ សុខជា** តំណាងនិយោជកនៅរោងចក្រ អូសៀន បានទទួលស្គាល់ថាការដោះស្រាយវិវាទការងាររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានលក្ខណៈឆាប់រហ័ស និងគួរឲ្យទុកចិត្តបានសម្រាប់និយោជក ។ " ប្រសិនបើក្រសួងការងារមិនអាចដោះស្រាយវិវាទការងារបាន ហើយប្រសិនបើគ្មានក្រុមប្រឹក្សាអាជ្ញាកណ្តាលទៀតនោះ យើងមានតែបញ្ជូនវិវាទនេះទៅតុលាការ។ " លោកបានមានប្រសាសន៍ ។ "នៅពេលដែលយើងបញ្ជូនសំណុំរឿងវិវាទការងារទៅតុលាការ វាអាចចំណាយលុយច្រើន ហើយកម្មករនិយោជិតប្រហែលមិនអាចមានលទ្ធភាពក្នុងការបង់ប្រាក់ដោះស្រាយនៅតុលាការទេ " ។

ដើម្បីធានាបានថា ផលប្រយោជន៍នៃសេវាដោះស្រាយវិវាទការងាររួមនៅមាននិរន្តភាព ការប្រឈមមុខផ្នែកទ្រទ្រង់ហិរញ្ញវត្ថុនាពេលអនាគតរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវតែជំនះឲ្យបានឆាប់ៗ។ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលជាស្ថាប័នគាំទ្រក្រុមប្រឹក្សាអាជ្ញាកណ្តាល កំពុងតែខិតខំព្យាយាមអស់ពីសមត្ថភាព ដើម្បីដោះស្រាយបញ្ហានេះ ដោយមានការពិគ្រោះយោបល់គ្នាយ៉ាងជិតស្និទ្ធិជាមួយរាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាគមនិយោជក ដូចជាសមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងសម្ព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា រួមទាំងសហព័ន្ធសហជីព និងសម្ព័ន្ធសហជីពនានាផងដែរ ។

នៅក្នុងឯកសារយុទ្ធសាស្ត្រនិរន្តរភាពរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលគំរូនៃនិរន្តរភាពផ្នែកហិរញ្ញវត្ថុក្នុងរយៈពេលវែងសម្រាប់សេវាកម្មក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរៀបចំឡើង ដើម្បីទទួលការគាំទ្រ និងអនុម័តដោយក្រុមភាគីដែលមានប្រយោជន៍ពាក់ព័ន្ធរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ យុទ្ធសាស្ត្រនេះ នឹងត្រូវបានបញ្ចប់នដើមត្រីមាសទី២ ឆ្នាំ២០១២ ហើយនៅពេលដែលបញ្ចប់នោះ នឹងដាក់ឲ្យសាធារណជនអាចទទួលយកបាន។ ប្រសិន បើត្រូវបានយកទៅអនុវត្តត្រឹមត្រូវនោះ ហើយ និងមានការសហការពីដៃគូទាំងអស់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល និរន្តរភាពផ្នែកហិរញ្ញវត្ថុក្រុមប្រឹក្សាអាជ្ញាកណ្តាលរយៈពេលវែងនេះ នឹងត្រូវបានធានាដោះស្រាយជាមិនខាន ។

ទោះជាយ៉ាងនេះក៏ដោយនៅក្នុងរយៈពេលខ្លី និងរយៈពេលមធ្យម (ពីខែមីនា ឆ្នាំ២០១៣ ដល់ឆ្នាំ២០១៦) ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងត្រូវការការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីប្រភពខាងក្រៅ ដើម្បីធានាការបន្តសេវាដោះស្រាយវិវាទរបស់ខ្លួន។ ក្នុងខណៈពេលដែលមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំពុងដាក់ចេញនូវសកម្មភាពជាច្រើននៅក្នុងការស្វែងរកប្រាក់ចំណូល ដើម្បីគាំទ្រសេវាក្រុមប្រឹក្សាអាជ្ញាកណ្តាល។ សកម្មភាពទាំងនោះរួមមានការលក់ឯកសារបោះពុម្ពផ្សាយក្រុមប្រឹក្សាអាជ្ញាកណ្តាល ការផ្តល់កម្មវិធីបណ្តុះបណ្តាលដោយយកកម្រៃ ការដាក់ផែនការអនុវត្តផ្តល់សេវាពិគ្រោះយោបល់ការងារ។ល។) ចំនួនប្រាក់ចំណូលដែលទទួលបានមិនគ្រប់គ្រាន់ក្នុងការទ្រទង់សេវាក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ ។ ដូច្នេះហើយ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល កំពុងពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បង្កើតភាពជាដៃគូជាមួយនឹងម្ចាស់ជំនួយអន្តរជាតិ ដើម្បីដោះស្រាយនូវភាពខ្វះខាតថវិកាដែលបានព្យាករណ៍ទុកនេះ ។

ក្នុងខណៈពេលដែលមិនមានការសន្យាឧបត្ថម្ភថវិកាជាក់លាក់ណាមួយនោះ នៅក្នុងរយៈពេលខ្លី និងរយៈពេលមធ្យម ដើម្បីគាំទ្រដល់សេវាក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងបន្តធ្វើការជាមួយក្រុមអ្នកប្រើប្រាស់សេវារបស់ខ្លួនដើម្បីប្រមូលនូវថវិការដែលចាំបាច់សម្រាប់ធានានូវភាពរីកចំរើនផ្នែកសេដ្ឋកិច្ចនិងសង្គមកិច្ចរយៈពេលវែងរបស់ប្រទេសកម្ពុជា និងប្រជាជនក្នុងប្រទេសនេះ ។

# តុលាការកម្ពុជាគាំទ្រសេចក្តីសម្រេចក្រុមប្រឹក្សាអាជ្ញាកណ្តាល

**នៅ**ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២ សាលាឧទ្ធរណ៍នៃប្រទេសកម្ពុជា បានគាំទ្រសេចក្តីសម្រេចក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ២២/១១-**ក្រុមហ៊ុន បានចាម៉ាត ខនស្រ្តាក់សិន** ។

សំណុំរឿងដែលមានការទាមទារចំនួន ៦ ចំណុចនេះបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ ។ នៅក្នុងសវនាការនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការផ្សះផ្សាជោគជ័យចំនួន៤ចំណុច ហើយបានកាត់សេចក្តីទៅលើចំណុចដែលនៅសេសសល់ចំនួន២ទៀត ទាក់ទងនឹងការទាមទារឲ្យយកថ្នាក់ដឹកនាំសហជីពចូលធ្វើការវិញ និងការបង់ប្រាក់ឈ្នួលរំលឹក ។ នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១១ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានចេញសេចក្តីសម្រេចដោយបង្គាប់ឲ្យក្រុមហ៊ុនយកថ្នាក់ដឹកនាំសហជីពចូលធ្វើការវិញ គឺលោក ឈុន ពៅ និង លោក ទេព ម៉ៅ ហើយបង់នូវប្រាក់ឈ្នួលរំលឹកដែលមិនទាន់បង់ ដោយគិតចាប់ពីថ្ងៃបរិច្ឆេទនៃការបណ្តេញចេញរហូតដល់ថ្ងៃបរិច្ឆេទនៃការទទួលយកធ្វើការវិញ ។ សេចក្តីសម្រេចនោះ បានចងកាតព្វកិច្ចបន្ទាប់ពីពុំមានការជំទាស់ក្នុងរយៈពេល៨ថ្ងៃ។ ក៏ប៉ុន្តែភាគីនិយោជកពុំបានអនុវត្តទៅតាមសេចក្តីសម្រេចនោះ ។

នៅថ្ងៃទី០៩ ខែឧសភាឆ្នាំ២០១១ **លោក សុខ សុវណ្ណដេត** ប្រធានសហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជាបានដាក់ពាក្យបណ្តឹងទៅតុលាការជំបូងខេត្តកំពត ដោយស្នើសុំអនុវត្តសេចក្តីសម្រេចក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលចងកាតព្វកិច្ចនោះ។

តុលាកាជំបូងខេត្តកំពត បានបញ្ជាឲ្យក្រុមហ៊ុនគោរពទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយហេតុផលថា ក្រុមហ៊ុនមិនបានដាក់ពាក្យប្តឹងជំទាស់ទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសេចក្តីបង្គាប់លេខ ២២/១១ នៅក្នុងរយៈពេល៨ថ្ងៃទេ។ ទោះជាយ៉ាងណាក៏ដោយក្រុមហ៊ុនមិនបានទទួលយកសេចក្តីសម្រេចរបស់តុលាការទេ ដោយលើកហេតុផលថា ក្រុមហ៊ុនបានទទួលសេចក្តីបង្គាប់នោះយឺត ហើយពុំមានពេលគ្រប់គ្រាន់ក្នុងការដាក់ពាក្យប្តឹងជំទាស់ទៅនឹងសេចក្តីបង្គាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះទេ ។

ក្រុមហ៊ុនបានដាក់បណ្តឹងបន្តទៅសាលាឧទ្ធរណ៍ចំពោះសេចក្តីសម្រេចឲ្យអនុវត្តដោយតុលាការខេត្តកំពត នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១១ ។

"ក្រុមហ៊ុនមិនបានដឹងអំពីថ្ងៃបរិច្ឆេទច្បាស់លាស់នៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាលទេ ហើយនៅពេលដែលក្រុមហ៊ុនបានទទួលសេចក្តីបង្គាប់នេះ ក្រុមហ៊ុនមានរយៈពេលតែ២ថ្ងៃប៉ុណ្ណោះសម្រាប់ដាក់ពាក្យប្តឹងជំទាស់ទៅនឹងសេចក្តីបង្គាប់នេះ។ លើសពីនេះទៅទៀត គឺត្រូវចំណាយពេលជាច្រើនម៉ោងក្នុងការធ្វើដំណើរពីខេត្តកំពតមកទីក្រុងភ្នំពេញ។"នេះបើតាមអំណះអំណាងរបស់**លោក អួន កុសល** ដែលជាមេធាវីរបស់ភាគីនិយោជកនៅក្នុងសវនាការនៅសាលាឧទ្ធរណ៍កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២ ។

នៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២ សាលាឧទ្ធរណ៍បានសម្រេចតម្កល់សេចក្តីសម្រេចរបស់តុលាការខេត្តកំពត ហើយបានបញ្ជាឲ្យក្រុមហ៊ុនគោរពទៅតាមសេចក្តីសម្រេចអាជ្ញាកណ្តាលនៅក្នុងសេចក្តីបង្គាប់លេខ ២២/១១ - **ក្រុមហ៊ុនបានចាម៉ាត ខនស្រ្តាក់សិន** ដោយផ្តល់ហេតុផលថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានគោរពទៅតាមនីតិវិធីត្រឹមត្រូវនៅក្នុងការសម្រេចរបស់ក្រុមប្រឹក្សានេះ ។

**លោក សុខ សុវណ្ណដេត** ប្រធាននៃសហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជាបាននិយាយថា សេចក្តីបង្គាប់អាជ្ញាកណ្តាលគឺអាចទទួលយកបានចំពោះរូបលោក ដោយសារតែសេចក្តីបង្គាប់អាជ្ញាកណ្តាលនេះ ផ្តល់នូវហេតុផលច្បាស់លាស់ ហើយបានពិចារណាដោយយុត្តិធម៌លើចំណុចនីមួយៗ ដែលភាគីបានលើកឡើងនៅក្នុងពេលសវនាការ ។

"ខ្ញុំគាំទ្រសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយសារតែក្រុមប្រឹក្សានេះ តែងតែធ្វើការវិនិច្ឆ័យដោយអនុលោមទៅតាមច្បាប់ការងារកម្ពុជា" នេះបើតាមសម្តីរបស់លោក ។

**លោក សុខ ឡោ** ដែលជានាយកប្រតិបត្តិមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បានចាត់ទុកការគាំទ្រទទួលយកនូវសេចក្តីបង្គាប់អាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ២១/១១ ដោយតុលាការខេត្តកំពត និងសាលាឧទ្ធរណ៍ថា ជាសាលក្រមដ៏សំខាន់ជាប្រវត្តិសាស្រ្តមួយ សម្រាប់ធ្វើឲ្យប្រសើរឡើងនូវការអនុវត្តន៍ច្បាប់នៅប្រទេសកម្ពុជា។

"សេចក្តីសង្ឃឹមរបស់យើងគឺថា តុលាការអាចផ្អែកទៅលើសេចក្តីសម្រេចដែលមានហេតុផលរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅពេលដែលពិចារណាការវិនិច្ឆ័យអំពីវិវាទការងារនានា ជាពិសេសគឺវិវាទការងារដែលអាចបង្កផលប៉ះពាល់លើកម្មករនិយោជិតរាប់ពាន់នាក់ និងប្រាក់ចំណេញយ៉ាងច្រើនរបស់ក្រុមហ៊ុននោះ។ " នេះបើតាមប្រសាសន៍របស់លោក។

ក្រមនីតិវិធីរដ្ឋប្បវេណី (មាត្រា៣៤៩ និងមាត្រា២៥១) ចែងពីការអនុវត្តន៍ដោយបង្ខំនូវសេចក្តីបង្គាប់អាជ្ញាកណ្តាលដែលក្លាយជាសេចក្តីបង្គាប់ចងកាតព្វកិច្ច និងចូលជាស្ថាពរ។ សេចក្តីបង្គាប់អាជ្ញាកណ្តាល ដែលក្លាយជាសេចក្តីបង្គាប់ចងកាតព្វកិច្ច និងចូលជាស្ថាពររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលកើតចេញពីការព្រមព្រៀងគ្នាទាំងសងខាងរបស់គូភាគី ឬក៏ការខកខានមិនបានដាក់ពាក្យប្តឹងជំទាស់ក្នុងរយៈពេល៨ថ្ងៃ បន្ទាប់ពីសេចក្តីបង្គាប់នេះបានចេញទៅ។

# អាជ្ញាកណ្តាល និងចៅក្រមពិភាក្សាគ្នាអំពីក្រមនីតិវិធីរដ្ឋប្បវេណីថ្មី



*ចៅក្រម សេង នាង បង្ហាញពីក្រមនីតិវិធីរដ្ឋប្បវេណីជូនដល់អាជ្ញាកណ្តាលនិងបុគ្គលិកក្រុមប្រឹក្សាអាជ្ញាកណ្តាល។*

**ម**ូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញ**ចៅក្រម សេង នាង** នៃតុលាការក្រុងភ្នំពេញ ដើម្បីពិភាក្សាជាមួយអាជ្ញាកណ្តាលនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល លើប្រធានបទដែលទាក់ទងទៅ និងបញ្ហានីតិវិធីផ្នែកច្បាប់មួយចំនួនដែលកើតចេញពីការអនុវត្តន៍ក្រមនីតិវិធីរដ្ឋប្បវេណី។ ព្រឹត្តិការណ៍នេះបានរៀបចំឡើងនៅថ្ងៃទី៣១ ខែមីនាឆ្នាំ២០១២ នៅការិយាល័យក្រុមប្រឹក្សាអាជ្ញាកណ្តាលដោយមានការចូលរួមពីសំណាក់អាជ្ញាកណ្តាល និងបុគ្គលិកគាំទ្ររបស់ក្រុមប្រឹក្សានេះ។

**លោក សុខ ឡោ** នាយកប្រតិបត្តិមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កិច្ច

*តទៅទំព័រ ៦*

## អាជ្ញាកណ្តាលនិង...

*តមកពីទំព័រ ៥*

ពិភាក្សានេះគឺជាកិច្ចសន្ទនាដ៏មានសារៈសំខាន់ដើម្បីសម្រេចបាននូវការអនុវត្តន៍ច្បាប់ដូចគ្នារវាងតុលាការ និងក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលការអនុវត្តន៍នេះនឹងផ្តល់ប្រយោជន៍ជូនដល់វិស័យឧស្សាហកម្ម និងកំលាំងពលកម្មរបស់ពួកគេនៅក្នុងវិស័យទាំងនោះ។

" វាចាំបាច់ណាស់ថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវពិភាក្សាបញ្ហាទាំងនេះដើម្បីជៀសវាងនូវការភ័ន្តច្រឡំដែលមិនចាំបាច់នានា ក្នុងការអនុវត្តន៍ច្បាប់ក្នុងសេចក្តីសម្រេចនាពេលអនាគតរបស់ក្រុមប្រឹក្សានេះ។ " នេះបើតាមប្រសាសន៍របស់លោក។

**ចៅក្រម សេង នាង** បានសំដែងការកោតសរសើរខ្ពស់ចំពោះក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលបានផ្តល់ឱកាសអោយលោកបានចូលរួមនូវការបណ្តុះបណ្តាលនេះ ហើយលោកក៏បានថ្លែងអំណរគុណដល់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ ដែលបានរៀបចំកម្មវិធីនេះឡើង។ លោកបានបន្ថែមថា កិច្ចសន្ទនានេះគួរតែធ្វើបន្តទៅមុខទៀតរវាងតុលាការ និងក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីឲ្យមានការយល់ការអនុវត្តន៍ច្បាប់កាន់តែប្រសើរឡើងរវាងស្ថាប័នទាំងពីរនេះ ពីព្រោះថា ការងាររបស់ស្ថាប័នទាំងពីរនេះមានទំនាក់ទំនងគ្នាទៅវិញទៅមក។

"សេចក្តីសំរេចដែលមានហេតុផលរបស់ក្រុមប្រឹក្សាកណ្តាល មានលក្ខណៈងាយស្រួល និងមានប្រសិទ្ធភាពក្នុងការដោះស្រាយក្នុងសំណុំរឿងរបស់ពួកគេ។ ឧទាហរណ៍ថា នៅក្នុងសំណុំរឿងដែលជាប់កាតព្វកិច្ចនោះ។ ភាគីអាចធ្វើការប្តឹងទៅតុលាការបើសិនជាភាគីណាមួយមិនអនុវត្តន៍តាមសេចក្តីសំរេចនោះ " លោកបានមានប្រសាសន៍។ ចៅក្រម សេង នាង បានមានប្រសាសន៍បន្ថែមទៀតថា "បន្ទាប់ពីទទួលបានសេចក្តីសំរេចនោះហើយតុលាការ និងចេញសាលក្រមអោយអនុវត្តន៍សេចក្តីសំរេចនោះ។ "

កិច្ចពិភាក្សានេះ បានរៀបចំឡើងជាផ្នែកមួយនៃកម្មវិធីបន្តអប់រំផ្នែកច្បាប់ដែលបានរៀបចំឡើងសម្រាប់ឲ្យអាជ្ញាកណ្តាល និងបុគ្គលិកគាំទ្ររបស់ពួកគាត់អាចទទួលបានព័ត៌មានបច្ចុប្បន្នភាពអំពីការប្រែប្រួលច្បាប់នានា និងដើម្បីលើកកម្ពស់ជំនាញរបស់ពួកគាត់ក្នុងការផ្តល់នូវសេវាកម្មប្រកបដោយគុណភាពខ្ពស់ជូនដល់សហគ្រាសវិស័យឯកជន និងកម្មករនិយោជិតក្នុងសហគ្រាសទាំងនោះ។

## អ្នកឯកទេសការងារធ្វើជាសមាជិក គណៈកម្មការក្នុងការប្រកួតអាជ្ញាកណ្តាលពាណិជ្ជកម្មអន្តរជាតិប្រឌិត ដំណាក់កាលដំបូង



*លោកស្រីជុំ ចរិយា និងលោកស្រី ខេម វណ្ណសុខ អ្នកឯកទេសច្បាប់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលកំពុងវាយតម្លៃបេក្ខជននៅសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។*

អ្នកឯកទេសច្បាប់៣រូប នៃមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បានចូលរួមជាគណៈកម្មការក្នុងការប្រកួតអាជ្ញាកណ្តាលពាណិជ្ជកម្មអន្តរជាតិប្រឌិតដំណាក់កាលដំបូងនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនៅថ្ងៃទី២ និងទី៣ ខែមីនា ឆ្នាំ២០១២។ កម្មវិធីនេះត្រូវបានរៀបចំឡើងដើម្បីពង្រឹងនូវជំនាញអាជ្ញាកណ្តាល និងការរៀបចំសំណុំរឿងសម្រាប់ឲ្យនិស្សិតច្បាប់មានសមត្ថភាពបង្ហាញសំណុំរឿងរបស់ពួកគេនៅចំពោះមុខសាវនាការអាជ្ញាកណ្តាល។

**លោក សុខ ឡោ** នាយកប្រតិបត្តិ **លោកស្រី ខេម វណ្ណសុខ** មន្ត្រីច្បាប់ជាន់ខ្ពស់ និង **លោកស្រី ជុំ ចរិយា** នាយកផ្នែកសេវាច្បាប់បានដើរតួជាអាជ្ញាកណ្តាលដើម្បីវាយតម្លៃនូវស្នាដៃរបស់និស្សិតប្រកួតចំនួន១២ក្រុម ។ ដែលក្នុងចំនោមនោះ និស្សិតចំនួន២ក្រុម ត្រូវបានជ្រើសរើសឲ្យតំណាងប្រទេសកម្ពុជា ដើម្បីចូលរួមកម្មវិធីប្រកួតអាជ្ញាកណ្តាល ពាណិជ្ជកម្មអន្តរជាតិប្រឌិតលើកទី៩ ដែលជាការប្រកួតប្រចាំឆ្នាំរវាងក្រុមនិស្សិត តំណាងឲ្យមហាវិទ្យាល័យច្បាប់នានាទូទាំងពិភពលោក ដែលបានប្រព្រឹត្តទៅនៅទីក្រុងហុងកុង នៅថ្ងៃទី១៩ ដល់ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១២។

នៅពេលប្រកួត ក្រុមនិស្សិតប្រកួតបានបង្ហាញអង្គហេតុ និងអំណះអំណាងរបស់ពួកគេ និងបានអះអាងជំទាស់ចំពោះអំណះអំណាងរបស់ក្រុមប្រកួតបដិបក្ស។

**លោកស្រី ជុំ ចរិយា** បាននិយាយថា ការចូលរួមនៅក្នុងកម្មវិធីនេះ វាជាការងារមួយផ្នែកដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលតែងតែធ្វើ ពីព្រោះថាក្រុមប្រឹក្សានេះតែងតែចែករំលែកចំណេះដឹងផ្នែកមជ្ឈត្តកម្ម និងច្បាប់ការងារ ជាពិសេសជាមួយនិស្សិតច្បាប់ ។

" ការប្រកួតនេះនឹងជួយនិស្សិតពង្រឹងជំនាញរបស់ពួកគេ ជាពិសេសទាក់ទងនឹងការរៀបចំសំណុំរឿង" លោកស្រីបានមានប្រសាសន៍បន្ថែមថា លោកស្រីសង្ឃឹមថា និស្សិតទាំងនេះនឹងប្រើជំនាញផ្នែកច្បាប់របស់ពួកគេ ហើយចែករំលែកជាមួយនឹងមិត្តភក្តិរបស់ពួកគេ ឬក៏បណ្តាជននានាដែលចង់សិក្សាអំពីអាជ្ញាកណ្តាល និងច្បាប់ការងារ ។

**លោក សុភ័ក្រ្ត** សាស្រ្តាចារ្យបង្រៀនផ្នែកអាជ្ញាកណ្តាល ពាណិជ្ជកម្មអន្តរជាតិ ក្នុងកម្មវិធីបរិញ្ញាប័ត្រច្បាប់ជាភាសាអង់គ្លេស នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្តនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាអ្នកសម្របសម្រួលកម្មវិធីនេះ បានមានប្រសាសន៍ថា កម្មវិធីនេះបានជួយឲ្យនិស្សិតទទួលនូវបទពិសោធន៍ និងគំនិតនៅក្នុងការប្រកួតជាមួយនឹងនិស្សិតច្បាប់ដទៃទៀត ជុំវិញពិភពលោក ។ " និស្សិតរបស់យើងបានទទួលនូវចំណេះដឹងជាក់ស្តែងពីអ្នកជំនាញផ្នែកច្បាប់របស់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលទាំងអស់គ្នាបានទទួលសញ្ញាបត្របរិញ្ញាប័ត្រច្បាប់ជាន់ខ្ពស់ពីក្រៅប្រទេស ហើយជាអ្នកអនុវត្តវិជ្ជាជីវៈផ្នែកច្បាប់ដែលមានជំនាញយ៉ាងទូលំទូលាយ " លោកបានមានប្រសាសន៍ដោយបានបន្ថែមថា ព្រឹត្តិការណ៍នេះមានសារៈសំខាន់សម្រាប់និស្សិតរបស់គាត់ ទោះបីជានិស្សិតទាំងនេះមិនបានឈ្នះជាជើងឯកនៅក្នុងពេលប្រកួតនៅទីក្រុងហុងកុងក៏ដោយ ។

ការប្រកួតអាជ្ញាកណ្តាលពាណិជ្ជកម្មអន្តរជាតិប្រឌិតលើកទី៩នេះ ត្រូវបានធ្វើឡើងនៅទីក្រុងហុងកុង ដែលមានតំណាងនិស្សិតច្បាប់ចំនួន២៦ប្រទេសមកពីប្រទេសជុំវិញពិភពលោកចូលរួម ។

## តើមានអ្វីថ្មី ?

## ក្រុមហ៊ុន ហ្គេប (Gap) បរិច្ចាគ ១០.០០០ ដុល្លារអាមេរិក

Gap Inc.

ក្រុមហ៊ុនហ្គេប (Gap) ដែលជាម៉ាកល្បីមួយនៅក្នុងពិភពលោកផ្នែកសំលៀកបំពាក់សម្រាប់បុរស ស្ត្រី កុមារ និងទារក បានបរិច្ចាគប្រាក់ចំនួន១០.០០០ដុល្លារអាមេរិក ដើម្បីគាំទ្រការងាររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងការដោះស្រាយវិវាទការងាររួមជូនដល់កម្មករនិយោជិត សហជីព និងរោងចក្រនានានៅប្រទេសកម្ពុជា ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាល ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ក្រុមហ៊ុនហ្គេប(Gap) ចំពោះការគាំទ្រ និងការបរិច្ចាគរបស់ក្រុមហ៊ុននេះជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីឲ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តផ្តល់សេវាបន្តទៀតក្នុងការធានាថាក្រុមប្រឹក្សាអាជ្ញាកណ្តាលជាស្ថាប័នដែលគួរជាទីទុកចិត្តសម្រាប់ដោះស្រាយវិវាទការងាររបស់ពួកគេ ។

**លោក សៀន ជុង (Sean Jung)** អ្នកគ្រប់គ្រងជាន់ខ្ពស់ផ្នែកទទួលខុសត្រូវសង្គមកិច្ចនិងបរិស្ថានប្រចាំតំបន់អាស៊ីខាងត្បូង និងខាងជើងរបស់ក្រុមហ៊ុនហ្គេប(Gap)បានបង្ហាញសេចក្តីសោមនស្សរីករាយរបស់លោកក្នុងការបរិច្ចាគជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលថា នេះជាផ្នែកមួយនៃការជួយឧបត្ថម្ភទៅដល់កម្មករនិយោជិតនិងដៃគូពាណិជ្ជកម្មដទៃទៀតដែលបានទទួលការដោះស្រាយដោយអហឹង្សាពីក្រុមប្រឹក្សាអាជ្ញាកណ្តាល។

«ក្រុមហ៊ុនយើងខ្ញុំមានមោទនភាពក្នុងការបរិច្ចាគជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយសារយើងខ្ញុំជឿជាក់ថាក្រុមប្រឹក្សានេះ គឺជាវេទិកាដ៏គួរឲ្យជឿជាក់សម្រាប់ការដោះស្រាយវិវាទការងារដោយសន្តិវិធីនៅប្រទេសកម្ពុជា ដែលផ្តល់សារៈប្រយោជន៍ដល់កម្មករនិយោជិតកម្ពុជា និងរោងចក្រផ្គត់ផ្គង់នានា ដែលយើងធ្វើការជាដៃគូជាមួយ។ ក្រុមហ៊ុនយើងខ្ញុំសូមលើកទឹកចិត្តឲ្យអ្នកបញ្ជាទិញដទៃទៀតចូលរួមជាមួយក្រុមហ៊ុនយើងខ្ញុំក្នុងការគាំទ្រក្រុមប្រឹក្សាអាជ្ញាកណ្តាល និងការងារដ៏វិជ្ជមានដែលក្រុមប្រឹក្សានេះអនុវត្ត” នេះបើតាមប្រសាសន៍របស់លោក ។

## ការបរិច្ចាគសៀវភៅពីក្រុមហ៊ុនបោះពុម្ពផ្សាយនាំមុខគេរបស់ប្រទេសអូស្ត្រាលី





នៅខែមីនា ឆ្នាំ២០១២ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលសៀវភៅ International Arbitration Act ឆ្នាំ១៩៧៤ ចំនួន៣៩ក្បាល ពីLexisNexis អូស្ត្រាលី។ សៀវភៅទាំងនោះគឺពន្យល់ដោយលម្អិតពីច្បាប់អូស្ត្រាលី ស្តីពីអាជ្ញាកណ្តាលអន្តរជាតិ ហើយនិងផ្តល់ជាមគ្គុទេសក៍ចំពោះសហគមន៍ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងការអភិវឌ្ឍន៍ច្បាប់អាជ្ញាកណ្តាលនៅប្រទេសកម្ពុជា ។

# ទទួលព័ត៌មានបច្ចុប្បន្នភាពស្តីពីច្បាប់ការងារ

ចំណេះដឹងផ្នែកការងារ គឺមានភាពចាំបាច់សម្រាប់អ្នកវិជ្ជាជីវៈផ្នែកធនធានមនុស្សនិយោជកមន្ត្រីសហជីព និងថ្នាក់ដឹកនាំសហគមន៍ដទៃទៀតដែលធ្វើការដោះស្រាយទៅនឹងបញ្ហាការងារ និងកិច្ចការដែលពាក់ព័ន្ធផ្សេងៗទៀត ។ ច្បាប់ការងារ និងលិខិតបទដ្ឋានការងារផ្សេងៗទៀតក៏មានការវិវត្តន៍ទន្ទឹមទៅ និងការបន្តវិវត្តន៍ទៅមុខរបស់សង្គម និងសេដ្ឋកិច្ចផងដែរ ។ ឧទាហរណ៍៖ តើអ្នកមានដឹងពីសេចក្តីសម្រេចថ្មីៗ ទាក់ទងនឹងកិច្ចសន្យាការងារ ការបង់ប្រាក់ឈ្នួល និងប្រាក់រង្វាន់ និងការឈប់សម្រាកដោយមានប្រាក់ឈ្នួលទេ? ដូច្នេះហើយ ទោះជាអ្នកជាអ្នកវិជ្ជាជីវៈផ្នែកធនធានមនុស្ស ជាអ្នកតស៊ូមតិផ្នែកការងារជានិស្សិតច្បាប់ជាសាស្ត្រាចារ្យ ឬក៏ជាអ្នកស្រាវជ្រាវក៏ដោយ វាចាំបាច់ណាស់ថា អ្នកត្រូវទទួលព័ត៌មានបច្ចុប្បន្នភាពពីការវិវត្តន៍នៅក្នុងច្បាប់ការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការបោះពុម្ពផ្សាយនូវធនធានឯកសារខាងក្រោមនេះ ដើម្បីជួយអ្នកសម្រេចបានគោលបំណងនេះ៖




- កម្រងសេចក្តីបង្គាប់ និងសេចក្តីបញ្ញាអាជ្ញាកណ្តាលលេខ ១-១១ (ភាសាអង់គ្លេស)
- កម្រងសេចក្តីបង្គាប់ និងសេចក្តីបញ្ញាលេខ ១-១៦ (ភាសាខ្មែរ)
- កម្រងច្បាប់ និងលិខិតបទដ្ឋានការងារឆ្នាំ២០១១ (ភាសាខ្មែរ)
- សៀវភៅ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល និងការដោះស្រាយវិវាទការងារ ឯកសារបោះពុម្ពផ្សាយទាំងអស់នេះមានលក់នៅក្នុងបណ្ណាគារ និងការិយាល័យក្រុមប្រឹក្សាអាជ្ញាកណ្តាល។

សូមទាក់ទងមកលោកស្រី សឹង្ហ សុភា មន្ត្រីសម្របសម្រួលផ្នែកបណ្តុះបណ្តាលរបស់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលឥឡូវនេះ សម្រាប់ជាវឯកសារបោះពុម្ពទាំងនេះតាមរយៈអ៊ីមែល៖ ssoeung@arbitrationcouncil.org ឬ ក៏តាមរយៈលេខទូរស័ព្ទ ០២៣ ៨៨ ១៨ ១៩ (លេខភ្ជាប់បន្ត១១០) ។

**រាល់ការជាវរបស់លោកអ្នក នឹងជួយទ្រទ្រង់ដល់វេទិកាសម្រាប់ការដោះស្រាយវិវាទការងារដោយសន្តិវិធីនៅប្រទេសកម្ពុជា ។**

ផ្ទះលេខ ៧២ ផ្លូវលេខ៥៩២ (កែងផ្លូវ ៣២៧) សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទលេខ : (+៨៥៥) ២៣ ៨៨១ ៨១៤
ទូរសារ : (+៨៥៥) ២៣ ៨៨១ ៩១៨
សារអេឡិចត្រូនិច : info@arbitrationcouncil.org
វិបសាយ : www.arbitrationcouncil.org

ប្រសិនបើមានព័ត៌មានដែលលោកអ្នកចង់ផ្សព្វផ្សាយក្នុងព្រឹត្តិបត្រក្រុមប្រឹក្សាអាជ្ញាកណ្តាល សូមទំនាក់ទំនង :
**លោក លី សុខហេង**
មន្ត្រីទំនាក់ទំនង
ទូរសព្ទលេខ : ០១២ ៩១១ ៩១៧
សារអេឡិចត្រូនិច : sly@arbitrationcouncil.org